# តើមនុស្សអាចកើតជាថ្មីបានដូចម្តេច?

## How Can A Man Be Born Again?

លោក ឈិក ស្មីត៍

"**ការកើតជាថ្មី**"

† *តើឃ្លានេះមានន័យយ៉ាងដូចម្តេច?*

† *ហេតុអ្វីបានជាព្រះយេស៊ូនិយាយថា ប្រសិនបើមនុស្សចង់ឃើញនគរស្ថានសួគ៌នោះ មនុស្សត្រូវតែកើតជាថ្មី?*

*សៀវភៅនេះនឹងពន្យល់អំពីលក្ខណៈខុសគ្នារវាង កំណើតនៃសាច់ឈាម (រូបកាយ) និងកំណើតនៃវិញ្ញាណ ព្រមទាំងប្រាប់អំពីហេតុដែលព្រះជាម្ចាស់បានបង្កើតមនុស្សមក។*

វាមិនមែននិយាយអំពីសាសនានោះទេ ប៉ុន្តែវានិយាយសំខាន់អំពីទំនាក់ទំនងរវាងមនុស្ស និងព្រះជាម្ចាស់ដែលបានបង្កើតមនុស្ស!

ដោយការលាក់កំបាំងខ្លួនឯងនៅក្នុងទីងងឹត មានបុរសម្នាក់បានដើរយ៉ាងប្រុងប្រយ័ត្នចូលមកជិតព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត ។ គាត់ជាអ្នកដឹកនាំសាសនាយូដាមួយរូបផងដែរ។ បុរសម្នាក់នេះបានរង់ចាំព្រះយេស៊ូរហូតដល់យប់ងងឹត ដោយសារតែគាត់មានសំណួរមួយដើម្បីសួរទៅកាន់ព្រះយេស៊ូ ហើយសំណួរនោះជាសំណួរដែលគាត់មិនចង់អោយនរណាម្នាក់ផ្សេងទៀតបានលឺឡើយ។ ដោយឈរមើលពីចម្ងាយ លោកនីកូដេមបានឃើញព្រះយេស៊ូគ្រិស្តធ្វើការអស្ចារ្យជាច្រើនបន្តបន្ទាប់គ្នា។ គាត់បានដឹងយ៉ាងច្បាស់ថា គ្មាននរណាម្នាក់អាចធ្វើការទាំងអស់នេះបានទេ លើកលែងតែអ្នកដែលមានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គង់ជាមួយអ្នកនោះ។ បន្ទាប់មកទៀត លោកនីកូដេមបានឃើញព្រះយេស៊ូកំពុងតែគង់នៅម្នាក់ឯង ដូច្នេះវាជាឱកាសដ៏ល្អសំរាប់គាត់ទៅជួបជាមួយព្រះយេស៊ូ ហើយសួរសំណួរទៅកាន់ព្រះអង្គ។

លោកនីកូដេមបានក៏ចាប់ផ្តើមសួរថា៖ “ លោកគ្រូ យើងខ្ញុំដឹងថា លោក គឺពិតជាចេញមកពីព្រះជាម្ចាស់ប្រាកដមែន ដ្បិតគ្មានអ្នកណាអាចធ្វើទីសំគាល់អស្ចារ្យដូចលោកបានធ្វើទាំងនោះទេ លើកលែងតែអ្នកដែលព្រះជាម្ចាស់គង់នៅជាមួយប៉ុណ្ណោះ ” ។ ព្រះយេស៊ូគ្រិស្ត ទ្រង់គឺជាព្រះ ហើយទ្រង់ជ្រាបដឹងគ្រប់កិច្ចការទាំងអស់។ ព្រះអង្គមានភាពរហ័សរហួនក្នុងការធ្វើកិច្ចការរបស់ទ្រង់ ដូច្នេះព្រះអង្គក៏បាននិយាយត្រង់ៗតែម្តងទៅកាន់លោកនីកូដេម ព្រោះព្រះអង្គទ្រង់ជ្រាបដឹងគ្រប់កិច្ចការទាំងអស់ដែលលោកនីកូដេមចង់ដឹង និងចង់បានពីទ្រង់ផងដែរ។ ដូច្នេះទ្រង់ក៏មានព្រះបន្ទូលតបទៅកាន់គាត់វិញថា៖ “ប្រសិនបើមនុស្សមិនកើតជាថ្មីនោះទេ នោះគេនឹងមិនអាចឃើញនគរឋានសួគ៌បានឡើយ” ។ នៅត្រង់ចំណុចនេះលោកនីកូដេមក៏ឆ្ងល់ ហើយក៏បានបន្តទូលសួរព្រះអង្គទៀតថា៖ "តើពាក្យថា “ការកើតជាថ្មី” មានន័យដូចម្តេច? "។ សំណួរនេះ គឺជាសំណួរមួយដែលមនុស្សជាច្រើនធ្លាប់បានសួរកន្លងមកជាច្រើនសតវត្សរ៍មកហើយ នៅពេលដែលគេសញ្ជឹងគិតពីព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងព្រះគម្ពីរយ៉ូហាន ៣:៣ ។

<u>តើ **‘ការកើតជាថ្មី’** មានន័យយ៉ាងដូចម្តេច?</u> តើលោកអ្នកដឹងទេថា កាលពីដើមដំបូងឡើយព្រះជាម្ចាស់បានបង្កើតមនុស្សមក អោយមានលក្ខណៈជាត្រីឯកដែរ គឺអោយមនុស្សមានវិញ្ញាណ គំនិត និង រូបកាយ។ ចិត្តគំនិត ត្រូវបានគ្រប់គ្រងដោយវិញ្ញាណដែលព្រះជាម្ចាស់បានប្រទានអោយ

ហើយបើកាលណាវិញ្ញាណនោះ ធ្វើជាអ្នកគ្រប់គ្រងលើជីវិតទាំងមូលរបស់មនុស្ស នោះមនុស្សនឹងរស់នៅរួមគ្នា និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ដែលបានបង្កើតមនុស្សមក។

ចំពោះជីវិតរុក្ខជាតិ គឺវាមានលក្ខណៈតែមួយប៉ុណ្ណោះ មានន័យថា រុក្ខជាតិ មានតែដើមដែលជារូបកាយតែប៉ុណ្ណោះ ហើយវាស្រូបយកសារធាតុចិញ្ចឹមមកពីក្នុងដី និង បរិយាកាសតាមរយៈដើមនោះឯង។ រីឯជីវិតសត្វវិញ គឺវាត្រូវបានបង្កើតឡើងដោយមានលក្ខណៈពីរយ៉ាង មានន័យថា វាមានទាំងរូបកាយ ព្រមទាំងមានស្មារតី ឬក៏គំនិតផងដែរ។ សត្វចិញ្ចឹមជីវិតដោយស៊ីសត្វដទៃទៀត ឬក៏ស៊ីរុក្ខជាតិជាអាហារ ហើយវាអាចធ្វើចលនាបានចម្ងាយឆ្ងាយៗ។ ដោយសារតែ សត្វមានស្មារតី ឬលក្ខណៈធម្មជាតិរបស់វា ព្រមទាំងចលនភាពរបស់វា ការទាំងនោះបញ្ជាក់ថាក្រុម សត្វមានលក្ខណៈខ្ពស់ជាងក្រុមរុក្ខជាតិ ឬបន្លែ។ ដោយឡែក នៅពេលព្រះជាម្ចាស់បង្កើតមនុស្ស ព្រះអង្គបានបង្កើតដោយអោយមានលក្ខណៈបីយ៉ាង គឺមានវិញ្ញាណ គំនិត និងរូបកាយ។ ដោយសារតែមនុស្សមានវិញ្ញាណនោះហើយដែលធ្វើអោយមនុស្សមានលក្ខណៈប្រសើរខ្ពស់ជាងសត្វ ឬរុក្ខជាតិ ហើយមនុស្សអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែរតាមរយៈវិញ្ញាណ។

ព្រះយេស៊ូមានព្រះបន្ទូលថាៈ ព្រះជាម្ចាស់ គឺជាវិញ្ញាណ ដូច្នេះអ្នកដែលថ្វាយបង្គំព្រះអង្គត្រូវតែថ្វាយបង្គំទ្រង់ដោយវិញ្ញាណ និងសេចក្តីពិត (យ៉ូហាន ៤:២៤)។ ដូចនេះ នៅពេលដែលព្រះជាម្ចាស់បង្កើតមនុស្សលោកមក (ដែលមានលក្ខណៈវិញ្ញាណ គំនិត និងរូបកាយ) គឺទ្រង់បានបង្កើតមនុស្សមក ក្នុងបំណងព្រះហឫទ័យចង់អោយមនុស្សរស់នៅប្រកបភាពជិតស្និតជាមួយនឹងទ្រង់។ មានខគម្ពីរដ៏ល្អមួយនៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ ៣:៨ “ រួចមកបានឮសំឡេងព្រះយេហូវ៉ាដ៏ជាព្រះ ដែលទ្រង់យាងក្នុងសួនច្បារនៅពេលថ្ងៃល្ងើយ....” មនុស្សបានជួបជាមួយព្រះជាម្ចាស់ និងបានរស់នៅរួមគ្នាជាមួយទ្រង់ តាមរយៈវិញ្ញាណរបស់មនុស្សនោះឯង។ នៅពេលដែលវិញ្ញាណរបស់មនុស្សបានស្លាប់ដោយសារអំពើបាប នោះជីវិតរបស់មនុស្សបានចាប់ផ្តើមថយចុះ រហូតដល់ដូចជាក្រុមពពួកសត្វដែរ។ គំនិតរបស់មនុស្សប្រែក្លាយទៅជាគំនិតមួយដែលចេះព្រួយបារម្ភអំពីតំរូវការខាងរាងកាយ និងការស្រេកឃ្លានផងដែរ។ វិញ្ញាណរបស់មនុស្សបានស្លាប់ ដោយសារតែការវាយលុកលុយនៃអំពើរបាបរបស់គេ។ កាលដើមដំបូងឡើយ ពេលព្រះជាម្ចាស់បង្កើតមនុស្សដំបូងនោះ មនុស្សរស់នៅក្នុងភាពខ្ពង់ខ្ពស់ និង នៅក្នុងបរិយាកាសដ៏បរិសុទ្ធមួយ។ គេមានរូបកាយរឹងមាំ និងមានសុខភាពល្អ ព្រមទាំងគ្មានជម្ងឺអ្វីទាំងអស់ ហើយដោយសារតែវិញ្ញាណរបស់មនុស្សមានជីវិត និងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដូចនេះគាត់មានទាំងការប្រកបជាមួយព្រះជាម្ចាស់ និងទាំងការរួបរួមគ្នាជាមួយព្រះទ្រង់ដែរ ។

ប៉ុន្តែ មានជំរើសមួយបានកើតឡើង។ តើមនុស្សបានរស់នៅរួមគ្នាជាមួយព្រះជាម្ចាស់ដោយសារ គាត់ស្រឡាញ់ទ្រង់? ឬមួយ មនុស្សបានរស់នៅរួមជាមួយព្រះជាម្ចាស់ មកពីមនុស្សគ្មានជំរើសផ្សេងទៀត?

ដើម្បីកំណត់មើលដួងចិត្តរបស់មនុស្សបាន ព្រះជាម្ចាស់បានដាក់ដើមឈើមួយដែលមានភាពទាក់ទាញយ៉ាងខ្លាំងណាស់នៅកណ្តាលសួនអេដែន។ វាជាដើមឈើដែលព្រះអង្គហាមមិនអោយបរិភោគផ្លែរបស់វាឡើយ ព្រោះបើមនុស្សបរិភោគផ្លែឈើនោះនឹងនាំអោយពួកគេស្លាប់ខាងវិញ្ញាណ។ ដូច្នេះ ឥឡូវនេះ មនុស្សត្រូវធ្វើការជ្រើសរើសមួយ។ ជំរើសមួយនោះគឺ តើមនុស្សចង់បន្តការរស់នៅប្រកបគ្នាជាមួយព្រះជាម្ចាស់? ឬមួយក៏ មនុស្សចង់បំពេញចំណង់តាមសាច់ឈាមលោកិយ៍របស់គាត់ ហើយត្រូវបែកចេញពីព្រះជាម្ចាស់?

គួរអោយសោកស្តាយណាស់ ដែលមនុស្ស(លោកអដាំ) បានជ្រើសរើសការរស់នៅតាមខាងសាច់ឈាម ហើយគាត់បានបរិភោគផ្លែឈើដែលព្រះអង្គបានហាមមិនអោយបរិភោគ។ តាមរយៈការដែលគាត់បានធ្វើនោះ វិញ្ញាណរបស់គាត់ត្រូវបានស្លាប់ ហើយចាប់ពីពេលនោះមកមនុស្សដែលព្រះជាម្ចាស់បានបង្កើតមកក្លាយទៅ ជាមនុស្សដែលមានលក្ខណៈតែពីរវិញ គឺរូបកាយ(សាច់ឈាម) និងព្រលឹង(គំនិត)។ ព្រះយេស៊ូមានព្រះបន្ទូលប្រាប់ លោកនីកូដេមថា៖ **អ្នកត្រូវតែកើតជាថ្មីឡើងវិញ** (យ៉ូហាន ៣:៧)។ យើងម្នាក់ៗត្រូវតែកើតជាថ្មី ខាងឯផ្នែកវិញ្ញាណ។ យើងបានកើតមកមានលក្ខណៈជាសាច់ឈាមនៃលោកិយ៍ ហើយយើងបានដាច់ចេញពីព្រះជាម្ចាស់រួចជាស្រេចហើយ ដូច្នេះយើងត្រូវតែកើតជាថ្មីខាងវិញ្ញាណឡើងវិញ ប្រសិនបើយើងចង់ដឹង និងចង់បានព្រះពរ និងអំណរដែលបានមកពីការរស់នៅរួមប្រកបជាមួយព្រះជាម្ចាស់។ មនុស្សដំបូង(លោកអដាំ)ដែលបានស្លាប់ខាងវិញ្ញាណដឹងច្បាស់ថា ការដែលធ្វើកិច្ចការល្អ ការកាន់តាមខាងសាសនាផ្សេងៗ ការកាន់តាមច្បាប់ ឬក៏ការអនុវត្តន៍តាមអ្វីមួយនោះ វាមិនអាចធ្វើអោយវិញ្ញាណដែលបានស្លាប់នោះរស់ឡើងវិញបានទេ ។ យើងអាចព្យាយាមធ្វើការផ្សេងៗ ដើម្បីអោយបានល្អ ប៉ុន្តែយើងនឹងមិនបានល្អគ្រប់គ្រាន់ល្មមឡើយ។ ព្រះយេស៊ូបានបន្តមានព្រះបន្ទូលជាមួយលោនីកូដេមទៀតថា៖ **ប្រសិនបើអ្នក មិនកើតជាថ្មីទេនោះ អ្នកនឹងមិនអាចឃើញ ព្រះរាជនៃស្ថានបរមសុខឡើយ** (យ៉ូហាន ៣:៣)។ មនុស្សយើងធម្មតាមិនអាចយល់អំពីការនេះឡើយ ហើយមនុស្សមិនមានសម្ថតភាពក្នុងការយល់អំពីការទាំងអស់នេះបានទេ។ សាវ័កប៉ូលបានសរសេរសំបុត្រទៅក្រុមជំនុំនៅក្រុងកូរិនថូសថា៖ *ចំពោះមនុស្សលោកគ្មាននរណាយល់អំពីមនុស្សបាន ក្រៅពីវិញ្ញាណដែលនៅក្នុងខ្លួនគេនោះទេ។ រីឯព្រះជាម្ចាស់ ក៏ដូច្នោះដែរ គ្មាននរណាម្នាក់យល់អំពីព្រះអង្គបាន ក្រៅពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះឡើយ។* ចំពោះយើង

*យើងពុំបានទទួលវិញ្ញាណលោកិយ៍ទេ គឺយើងបានទទួលព្រះវិញ្ញាណដែលមកពីព្រះជាម្ចាស់ ដើម្បីអោយបានស្គាល់អ្វីដែលព្រះអង្គប្រោសប្រទានអោយយើង។ យើងនិយាយសេចក្តីទាំងនេះ ដោយមិនប្រើពាក្យពេជន៍ដែលប្រាជ្ញាមនុស្សបង្រៀននោះឡើយ គឺយើងប្រើតែពាក្យណាដែលព្រះវិញ្ញាណបង្រៀន ដើម្បីពន្យល់សេចក្តីពិតខាងវិញ្ញាណដល់មនុស្សដែលបានទទួលព្រះវិញ្ញាណ។ រីឯមនុស្សមិនបានទទួលព្រះវិញ្ញាណ ក៏ពុំអាចទទួលសេចក្តីណាដែលមកពីព្រះវិញ្ញាណបានដែរ ព្រោះគេយល់ថាសេចក្តីទាំងនោះជារឿងលេលា ហើយគេពុំអាចយល់បានទេ មានតែព្រះវិញ្ញាណប៉ុណ្ណោះដែលប្រទានអោយមនុស្សយើងអាចវិនិច្ឆ័យសេចក្តីទាំងនោះបាន* (១ កូរិនថូស ២:១១-១៤)។ ដូចជាអ្វីដែលសាវ័កប៉ូលបាននិយាយអញ្ចឹង ធម្មតាមនុស្សយើងមិនអាចដឹង ឬយល់អំពីកិច្ចការខាងឯវិញ្ញាណឡើយ ហើយចំពោះយើងជាមនុស្សវិញ វាបែរជាមានលក្ខណៈលេលា ហើយពិបាកក្នុងការទទួលជឿទៅវិញ ។ វាពិតជាមានការពិបាកក្នុងការទំនាក់ទំនងជាមួយព្រះជាម្ចាស់ នៅពេលដែលយើងមិនយល់ដឹងច្បាស់លាស់ អំពីភាពខុសគ្នារវាងព្រះវិញ្ញាណដែលគ្រប់គ្រងលើមនុស្ស និងសាច់ឈាមគ្រប់គ្រងលើមនុស្ស។ តើលោកអ្នកធ្លាប់ចាប់អារម្មណ៍ដែរឬទេថា វាពិតជាពិបាកក្នុងការពន្យល់អ្វីមួយទៅកូនក្មេង? វាអាចធ្វើអោយយើងឆាប់មួរម៉ៅបាន ពីព្រោះយើងគិតថា ហេតុអ្វីបានជាក្មេងនេះមិនយល់អញ្ចឹង? ខ្ញុំបានពន្យល់ច្បាស់មែនទែន ហើយការនេះជាការធម្មតាៗទេតើ! ហេតុអ្វីបានជាក្មេងនេះនៅតែមិនយល់សោះអញ្ចឹង? ចំពោះខាងឯផ្នែកវិញ្ញាណ មនុស្សក៏ប្រៀបដូចជាកូនក្មេងម្នាក់អញ្ចឹងដែរ ។ ព្រះគម្ពីរបានប្រាប់យើងថា មនុស្សធម្មតាមិនអាចយល់អ្វីៗអំពីផ្នែកឯវិញ្ញាណបានទេពីព្រោះពួកគេត្រូវការមានការបង្ហាត់បង្រៀនខាងពីព្រះវិញ្ញាណ។ ហេតុនេះហើយបានជាព្រះយេស៊ូមានព្រះបន្ទូលថា៖ អ្នកត្រូវតែកើតជាថ្មីឡើងវិញ ប្រសិនបើអ្នកចង់ឃើញនគរស្ថានសួគ៌។ ប្រសិនបើលោកអ្នកនឹងចង់ឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើស្ថានសួគ៌ ការនោះទាមទារអោយលោកអ្នកមានការកើតជាថ្មីខាងឯវិញ្ញាណ។ ***ដូច្នេះ លោកអ្នកត្រូវតែកើតជាថ្មីម្តងទៀត។***

បន្ទាប់មកលោកនីកូដេមបានសួរព្រះយេស៊ូទៀតថា៖ ‘**តើអោយខ្ញុំកើតជាថ្មីដូចម្តេចបាន**? **តើការកើតជាថ្មីនេះតាមរបៀបណាដែរទៅ**? **ហើយតើការទាំងអស់នេះកើតមានដូចម្តេចបាន**?’ ។ ព្រះយេស៊ូបានពន្យល់ដោយប្រើប្រាស់ឧទាហរណ៍មួយ ដើម្បីអោយលោកនីកូដេមអាចយល់បាន។ ព្រះអង្គមានព្រះបន្ទូលប្រាប់លោកនីកូដេមអំពីរឿងមួយនៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ ដែលទ្រង់បានដកស្រង់ចេញមកពីកណ្ឌគម្ពីរជនគណនា។ នៅពេលដែលកូនចៅអ៊ីស្រាអែលនៅវាលរហោស្ថានពួកគេបានចាប់ផ្តើមរអ៊ូប្រឆាំងនឹងព្រះជាម្ចាស់ និងលោកម៉ូសេ។ ពួកគេនាំគ្នានិយាយថា៖ ព្រះជាម្ចាស់

និងលោកម៉ូសេ បាននាំពួកយើងចេញពីស្រុកអេស៊ីបមក ដើម្បីសម្លាប់យើងនៅទីរហោស្ថាននេះ។ យើងអត់មានអាហារអ្វីផ្សេង ក្រៅពីនំម៉ាណាដ៏ធុញទ្រាន់នេះឡើយ(ជនគណនា ២១:៥)។

ដោយសារតែពួកគេបាននិយាយរអ៊ូរទាំ ព្រមទាំងតវ៉ាប្រឆាំង នឹងព្រះជាម្ចាស់ដូច្នេះ ព្រះអង្គបានដាក់ទោសពួកគេ ដោយអោយមានសត្វពស់ដែលមានពិសសាហាវចូលក្នុងជំរុំរបស់ពួកគេ ហើយបន្ទាប់មកទៀត ក្នុងពេលដ៏ខ្លីមួយ មានមនុស្សក្នុងចំណោមជនជាតិអ៊ីស្រាអែលជាច្រើន បានស្លាប់និងរបួស ដោយសារតែសត្វពស់ពិសទាំងនោះចឹក។ ពេលនោះប្រជាជនអ៊ីស្រាអែល នាំគ្នារត់ទៅរកលោកម៉ូសេ ហើយបានសុំទោសគាត់ ព្រមទាំងអង្វរគាត់អោយអធិស្ឋានទៅកាន់ព្រះជាម្ចាស់សំរាប់ពួកគេ។ ពេលនោះលោកម៉ូសេបានទូលសុំអោយព្រះជាម្ចាស់ព្យាបាលប្រជាជនទាំងនោះ។ ទោះបីជាយ៉ាងនេះក្តី ព្រះជាម្ចាស់ពុំបានព្យាបាលប្រជាជនភ្លាមៗតែម្តងនោះទេ ព្រះអង្គបានដាក់ជំរើសមួយសំរាប់ពួកគេ។ ព្រះអង្គបានធ្វើអោយប្រជាជនអ៊ីស្រាអែលដែលត្រូវពស់ចឹកជ្រើសរើស មានន័យថាការបានជាសះស្បើយរបស់ពួកគេ គឺស្ថិតនៅលើការសំរេចចិត្តផ្ទាល់របស់ខ្លួនឯង។ នៅក្នុងព្រះគម្ពីរជនគណនា ២១:៨ បានចែងថា៖ **ហើយព្រះយេហូវ៉ាទ្រង់មានបន្ទូលមកលោកម៉ូសេថា ចូរធ្វើពស់ភ្លើងមួយ ភ្ជាប់នៅលើបង្គោលទៅ ដើម្បីអោយកាលណាអស់អ្នកដែលត្រូវពស់ចឹកគេក្រឡេកមើលទៅឃើញ នោះគេនឹងបានជា ហើយរស់នៅ** ។ ពេលនោះលោកម៉ូសេក៏បានធ្វើពស់លង្ហិន បោះភ្ជាប់ទៅនឹងបង្គោលមួយ ហើយគាត់បានដាក់នៅកណ្តាលជំរំរបស់ពួកគេ។ បន្ទាប់មកទៀត លោកម៉ូសេបានប្រកាសប្រាប់ដល់អស់អ្នកដែលត្រូវបានពស់ចឹកទាំងអស់នោះថា អោយសំលឹងមើលទៅកាន់ពស់លង្ហិនដែលនៅជាប់នឹងបង្គោលកណ្តាលជំរំ។ បន្ទាប់មកអស់អ្នកទាំងនោះបានសំលឹងមើលទៅពស់នោះ រួចហើយពួកគេក៏បានជាសះស្បើយភ្លាមតែម្តង។

នៅក្នុងព្រះគម្ពីរ លង្ហិន គឺជាសញ្ញាដែលតំណាងអោយ*ការកាត់ទោស ឬការវិនិច្ឆ័យទោសរបស់ព្រះជាម្ចាស់ចំពោះមនុស្ស*។ ប្រជាជនអ៊ីស្រាអែលមានអាសនៈមួយធ្វើពីលង្ហិន ដែលជាអាសនៈសំរាប់ធ្វើយញ្ញបូជា (នៅក្នុង ២ពង្សាវតាក្សត្រ ១៦:១៥)។ ចំពោះសត្វពស់វិញ គឺភាគច្រើននៅក្នុងព្រះគម្ពីរតំណាងអោយ*អំពើបាប*។ មានឧទាហរណ៍មួយ អំពីសត្វពស់ដែលបានល្បួងស្ត្រី និងបុរសដំបូង (នាងអេវ៉ា និងលោកអដាំ) នៅក្នុងសួនច្បារអេដែន ក្នុងលោកុប្បត្តិ ៣:១៣ ។ ទោះបីជានៅក្នុងរូបភាពយ៉ាងនេះក៏ដោយ ក៏ការលើកពស់លង្ហិនដែលនៅជាប់នឹងបង្គោលនោះ សំដៅទៅលើឈើឆ្កាងដែលព្រះយេស៊ូគ្រិស្តនឹងត្រូវបានគេឆ្កាង។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ ‘ **នោះកូនមនុស្សនឹងត្រូវគេលើកលោកឡើងយ៉ាងនោះដែរ**’ (យ៉ូហាន ៣:១៤)។ បន្ទាប់មកមានម្តងទៀតដែលទ្រង់មានបន្ទូលនៅក្នុងព្រះគម្ពីរយ៉ូហាន ១២:៣២ ថា៖ **ឯខ្ញុំ បើសិនជាខ្ញុំត្រូវលើកពីដីឡើង នោះខ្ញុំនឹងទាញមនុស្ស**

**ទាំងអស់មកឯខ្ញុំ។** ទីកន្លែងនេះ ព្រះយេស៊ូកំពុងតែនិយាយអំពីរបៀបដែលទ្រង់នឹងសោយទិវង្គតនៅលើឈើឆ្កាង។ ដូច្នេះ រូបពស់លង្ហិនដែលនៅជាប់នឹងបង្គោលនោះ គឺជាសញ្ញាតំណាងអោយអំពើបាបរបស់យើងដែលត្រូវបានកាត់ទោស ដោយសារព្រះអម្ចាស់ដែលនៅលើឈើឆ្កាង។ ដូចដែលលោកម៉ូសេបានលើកពស់លង្ហិននៅក្នុងវាលរហោស្ថាន នោះបុត្រមនុស្សនឹងត្រូវបានគេលើកទ្រង់ឡើងដែរ។

**តើមនុស្សអាចកើតជាថ្មីបានដូចម្តេច?** មនុស្សអាចកើតជាថ្មីបានដោយសារ របៀបដែលព្រះជាម្ចាស់បានផ្តល់មកអោយយើង តាមរយៈការសុគតរបស់ព្រះរាជបុត្រាតែមួយគត់របស់ទ្រង់ គឺព្រះយេស៊ូគ្រិស្ត។ ព្រះយេស៊ូសុខចិត្តទទួលយកនូវការវិនិច្ឆ័យទោស ព្រោះតែអំពើបាបរបស់យើងគ្រប់ៗគ្នា គឺព្រះអង្គទ្រង់បានសុគតនៅកន្លែងដែលទ្រង់មិនស័ក្តិសមទទួល ហើយយើងវិញទេដែលស័ក្តិសមនឹងទទួលការកាត់ទោសនៅលើឈើឆ្កាង ដោយព្រោះអំពើបាបរបស់យើង។ នៅពេលដែលយើងយល់ និងព្រមទទួលស្គាល់គ្រប់កិច្ចការដែលព្រះយេស៊ូបានធ្វើ ហើយសំលឹងមើលទៅកាន់ព្រះអង្គដែលបានសុគតលើឈើឆ្កាងដោយមានជំនឿ នោះយើងនឹងដឹងកាន់តែច្បាស់ថា ព្រះអង្គពិតបានសុគត ដើម្បីលះបាបរបស់យើងពិតប្រាកដមែន ហើយទ្រង់សុខចិត្តទទួលយកការវិនិច្ឆ័យទោសជំនួសជីវិតយើង ដើម្បីអោយយើងម្នាក់ៗមានជីវិតអស់កល្បជានិច្ចជាមួយទ្រង់។

ស្រមៃមើលថា ប្រសិនបើលោកអ្នកកំពុងតែរស់នៅជាមួយប្រជាជនអ៊ីស្រាអែល ប្រហែលជា ៣៨០០ ឆ្នាំមុន ហើយជាពេលដែលមានសត្វពស់ជាច្រើនបានចូលក្នុងជំរុំរបស់លោកអ្នក។ មានថ្ងៃមួយ លោកអ្នកកំពុងតែអង្គុយនិយាយលេងជាមួយមិត្តភក្តិនៅក្នុងជំរំរបស់លោកអ្នក ហើយស្រាប់តែមានសត្វពស់មួយលូនចូលមក ហើយបានចឹកខាំជើងមិត្តភក្តិរបស់លោកអ្នក។ លោកអ្នកក៏បានឈរមើលគាត់ ដោយមិនដឹងថាត្រូវជួយយ៉ាងដូចម្តេច ហើយស្រាប់តែជើងរបស់គាត់ក៏ចាប់ផ្តើមហើមនិងមួយសន្ទុះក្រោយមក មិត្តភក្តិរបស់លោកអ្នកបានប្រកាច់ដួល ដោយសារពិសរបស់សត្វពស់។ ពេលនោះ លោកអ្នកក៏បានប្រញាប់ចាប់ទាញគាត់ចេញពីជំរុំយ៉ាងលឿន ហើយស្រែកខ្លាំងៗប្រាប់មិត្តភិក្តរបស់លោកអ្នកថា៖ ‘សូមអ្នកសំលឹងមើលទៅរូបសត្វពស់លង្ហិនដែលលោកម៉ូសេបានដាក់ជាប់នឹងបង្គោលនៅកណ្តាលជំរំនោះទៅ’ ។ ប៉ុន្តែមិត្តភក្តិនោះឆ្លើយតបវិញថា ៖ ‘ ខ្ញុំមិនយល់សោះថាតើការនេះនឹងអាចជួយខ្ញុំបានឬ? ’ ។ បន្ទាប់មក លោកអ្នកស្រែកឡើងម្តងទៀតថា៖ “ សូមកុំប្រកែកជាមួយខ្ញុំឡើយ គ្រាន់តែសំលឹងមើលទៅបានហើយ ” ។ ផ្ទុយទៅវិញ មិត្តភក្តិនោះក៏បានតបមកវិញទៀតថា ៖ ‘ ខ្ញុំមិនយល់សោះ! តើការដែលសំលឹងមើលរូបពស់នៅជាប់បង្គោលនេះ នឹងអាចជួយខ្ញុំបាន? ខ្ញុំជិតស្លាប់ឥឡូវហើយ ’ ។ លោកអ្នកនៅតែបន្តព្យាយាមពន្យល់គាត់ទាំងពិបាកថា៖ “ ខ្ញុំក៏មិនដឹងអំពីការនេះដែរ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា នៅជុំវិញពួកយើងមានមនុស្សជាច្រើនដែលកំពុងតែស្លាប់

ដូចជាមិត្តឯងដែរ។ ប៉ុន្តែពួកគេបានសំលឹងមើលទៅ រូបសត្វពស់លង្ហិនដែលនៅជាប់នឹងបង្គោលនោះ ហើយឥឡូវនេះពួកគេបានជាសះស្បើយហើយ។ សូមអ្នកមេត្តាសំលឹងមើលរូបពស់នោះទៅ! ’ ។ ប៉ុន្តែ មិត្តភក្តិរបស់លោកអ្នកនៅតែបដិសេធថា៖ ‘នេះជារឿងល្ងីល្ងើមួយប៉ុណ្ណោះ ខ្ញុំមិនយកចិត្តទុកដាក់នឹងវាទេ ’ ។

បន្ទាប់មកមិត្តភក្តិរបស់អ្នកក៏បានដាច់ខ្យល់ស្លាប់ទៅ ហើយពេលនោះលោកអ្នកដូចជាមិនចង់ទទួលជឿអំពីការអ្វីដែលទើបតែនឹងកើតមានដល់មិត្តភក្តិរបស់លោកអ្នកឡើយ។ លោកអ្នកមិនបានសុំអោយគាត់ធ្វើអ្វីពិបាកនោះទេ គឺលោកអ្នកគ្រាន់តែចង់អោយគាត់សំលឹងមើលទៅកាន់រូបសត្វពស់លង្ហិននោះតែប៉ុណ្ណោះ។ គាត់មិនចាំបាច់យល់អំពីរបៀបដែលរូបសត្វពស់ជួយព្យាបាលនោះឡើយ គឺគាត់គ្រាន់តែជឿ ហើយសំលឹងមើល ដើម្បីទទួលបានផលព្យាបាលនោះ។

ដូចគ្នាដែរ ព្រះយេស៊ូបានសុគតសំរាប់អំពើរបាបរបស់យើង ប៉ុន្តែយើងមិនចាំបាច់យល់អំពីការដែលនាំអោយព្រះអង្គធ្វើដូច្នេះដែរ។ យើងមិនត្រូវការដឹង ឬ យល់អំពីឫសគល់ នៃការបំផ្លាស់បំប្រែនោះទេ ប៉ុន្តែអ្វីដែលយើងត្រូវតែដឹងនោះ គឺយើងត្រូវដឹងថា ការនោះជាការដែលពិតប្រាកដមែន។ ដូចជាប្រជាជនអ៊ីស្រាអែលនៅវាលរហោស្ថានដែរ យើងមិនចាំបាច់យល់ពីរបៀបនៃការសង្គ្រោះ ដើម្បីទទួលភាពរីករាយអំពីលទ្ធផលរបស់វានោះទេ។ យើងអាចរស់នៅរួមគ្នា និងមានមនសិការរួមគ្នា ព្រមទាំងប្រកបគ្នាជាមួយព្រះជាម្ចាស់បានផងដែរ។ យើងអាចដឹងថា តើជីវិតដែលអស់កល្បជានិច្ច និងជីវិតដែលមានសេរីភាពចេញពីអំពើបាបនោះ វាមានលក្ខណៈល្អអស្ចារ្យយ៉ាងណាដែរ។ ព្រះយេស៊ូបានពន្យល់អំពីរបៀបនៃកើតជាថ្មីឡើងវិញ ហើយទ្រង់មានព្រះបន្ទូលថា៖ **ហើយដែលលោកម៉ូសេបានលើកសត្វពស់ឡើងនៅទីរហោស្ថានយ៉ាងណា នោះកូនមនុស្សនឹងត្រូវគេលើកលោកឡើងយ៉ាងនោះដែរ ដើម្បីអោយអស់អ្នកណាដែលជឿដល់កូនមនុស្សនោះ មិនត្រូវវិនាសឡើយ គឺអោយមានជីវិតអស់កល្បជានិច្ចវិញ** (យ៉ូហាន ៣:១៤-១៥) ។

ដូច្នេះ ប្រសិនបើគ្មានការកើតជាថ្មីទេ នោះលោកអ្នកនឹងប្រៀបបានដូចជា មនុស្សម្នាក់ដែលរស់នៅមានលក្ខណៈតែ ពីរ ភាគបី (២/៣) នៃជីវិតទាំងមូលប៉ុណ្ណោះ។ មនុស្សយើងដឹងនៅក្នុងចិត្តនិងឆន្ទៈរបស់គេ គឺគេដឹងថា មានអ្វីមួយដែលនៅខ្វះក្នុងជីវិតរបស់គេ ហើយពួកគេតែងតែព្យាយាមស្វែងរកអ្វីមួយមកបំពេញចន្លោះនោះ។ ប៉ុន្តែ មានបញ្ហាមួយ គឺថាមនុស្សបានព្យាយាមស្វែងរកអ្វីមួយមកបំពេញចន្លោះនោះ គឺពួកគេស្វែងរកដោយប្រើប្រាស់កិច្ចការខាងឯសាច់ឈាមទៅវិញ ឬក៏ប្រើប្រាស់តាមអារម្មណ៍ដែលពួកគេមាននៅក្នុងបទពិសោធន៍ផ្ទាល់ខ្លួន។ ប៉ុន្តែសរុបមក ទោះបីជាមនុស្សព្យាយាមស្វែងរកការទាំងនោះដោយបំពេញចិត្តរបស់គេ ដោយការបំពេញការសប្បាយខាងឯសាច់

ឈាម ឬក៏បំពេញអារម្មណ៍របស់គេយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែមិនអាចបំពេញការនោះបានដែរ គឺពួកគេនៅតែមានអារម្មណ៍ថា ពួកគេនៅមានខ្វះអ្វីមួយ ពីព្រោះគ្មានអ្វីអាចបំពេញជីវិតខាងវិញ្ញាណបានទេ លុះត្រាតែមនុស្សនោះមានការកើតជាថ្មីក្នុងព្រះវិញ្ញាណ។

ព្រះជាម្ចាស់បានបង្កើតមនុស្សមក គឺដើម្បីអោយពួកគេថ្វាយបង្គំព្រះអង្គ។ ប្រសិនបើយើងទាំងអស់គ្នាមិនថ្វាយបង្គំព្រះពិត ជាព្រះដែលមានព្រះជន្មគង់នៅនោះទេ នោះយើងកំពុងតែថ្វាយបង្គំព្រះផ្សេងៗ ឬក៏របស់របរផ្សេងៗទៀតដូចជាៈ ឡានរបស់លោកអ្នក ផ្ទះ លុយ ឬក៏ របស់របរផ្សេងទៀតជាច្រើន ដែលលោកអ្នកគិតថា វាសំខាន់ជាងព្រះជាម្ចាស់ដែលបានបង្កើតលោកអ្នកមក។ ប៉ុន្តែ នេះជាការធម្មតាទេ មនុស្សទាំងអស់កើតមកសុទ្ធតែមានការថ្វាយបង្គំទាំងនេះដូចៗគ្នារួចស្រេចទៅហើយ។ លោកអ្នកប្រហែលគិតថា នេះគឺជាការធម្មតាសាមញ្ញតែប៉ុណ្ណោះ ហើយលោកអ្នកប្រហែលជាមិនយល់អំពី **តើបើសិនជាមនុស្សគ្រាន់តែជឿលើព្រះយេស៊ូគ្រិស្ត ហើយអោយមនុស្សនោះអាចកើតជាថ្មីក្នុងព្រះវិញ្ញាណដូចម្តេចបាន**? បាទ! ត្រឹមត្រូវហើយ គឺព្រះជាម្ចាស់បានអោយការនេះមានលក្ខណៈសាមញ្ញធម្មតាដូច្នេះឯង គឺសម្បីតែកូនក្មេងតូចៗក៏អាចទទួលការកើតជាថ្មីក្នុងព្រះវិញ្ញាណបានដែរ។ ព្រះយេស៊ូបានពន្យល់ដល់លោកនីកូដេមថាៈ **ព្រះជាម្ចាស់ស្រឡាញ់ពិភពលោកនេះខ្លាំងណាស់ គឺជាពិភពលោកដែលកំពុងតែត្រូវអំពើបាបបំផ្លាញ ហើយនឹងត្រូវវិនាសដែលជាលទ្ធផលនៃអំពើបាប។ ប៉ុន្តែអស់អ្នកណាដែលជឿលើព្រះយេស៊ូ នោះនឹងមិនត្រូវវិនាសឡើយ ប៉ុន្តែគេនឹងមានជីវិតអស់កល្បជានិច្ចវិញ** (យ៉ូហាន ៣:១៦)។ ខ្ញុំកំពុងតែគិតម្តងទៀតអំពីប្រជាជាតិអ៊ីស្រាអែលដែលគេកំពុងតែវង្វេងនៅក្នុងវាលរហោស្ថាន ពួកគេបានស្តីបន្ទោសអោយព្រះជាម្ចាស់ចំពោះបញ្ហាដែលពួកគេជួបប្រទះ ហើយនិយាយរអ៊ូរទាំ និងតវ៉ាប្រឆាំងជាមួយព្រះអង្គ ក៏ព្រោះតែភាពឥតបានការរបស់ពួកគេដែរ។ ប៉ុន្តែ តាមពិតពួកគេទៅវិញទេដែលសក្តិសមនឹងទទួលការបន្ទោសទាំងនោះ។ *មនុស្សយើងពិតជាពិបាកណាស់* ។ យើងបានបោះបង់ចោលព្រះជាម្ចាស់ ហើយរស់នៅតាមរបៀបនៃសាច់ឈាមលោកិយ៍របស់យើង ។ បន្ទាប់មកយើងចាប់ផ្តើមជួបប្រទះនឹងការឈឺចាប់ក្នុងជីវិតសាច់ឈាមនោះ ការខ្វះខាតខាងព្រលឹងវិញ្ញាណ ចិត្តកំហឹង និងការលំបាកលំបិនជាច្រើន។ ជីវិតខាងសាច់ឈាមលោកិយ៍ គឺមាននាំអោយទៅកាន់សេចក្តីស្លាប់ប៉ុណ្ណោះ។ ដូចគ្នានឹងសត្វពស់ដែលមានពិសដែលបានចឹក ហើយវានឹងបំផ្លាញលោកអ្នក ព្រមទាំងធ្វើអោយលោកអ្នកត្រូវវិនាសអន្តរាយទៀតផង។ ប៉ុន្តែចំពោះការរស់នៅ ក្នុងវាលរហោស្ថាន និងការជួបភាពលំបាកវេទនារបស់ជនជាតិអ៊ីស្រាអែលនោះមិនមែនជាគោលបំណងដើមដំបូងរបស់ព្រះជាម្ចាស់ឡើយ ហើយក៏មិនមែនជាផែនការរបស់ព្រះអង្គដែរ។ ព្រះជាម្ចាស់មានព្រះហឫទ័យចង់នាំពួកគេអោយបានចូលក្នុងទឹកដីសន្យា គឺជាទឹកដីមួយដែល

ពួកគេអាចទទួលអំណរពិតប្រាកដ និងព្រះពរដ៏លើសលប់នៅក្នុងទឹកដីនោះ ដូច្នេះការទាំងនោះហើយ ជាព្រះពរដែលព្រះអង្គបានសន្យាជាមួយបុព្វបុរសរបស់ពួកគេ គឺតាំងពីលោកអប្រាហាំមកម្លេះ។ ប៉ុន្តែ ពួកគេបានបដិសេធសក្ខីភាពរបស់លោកកាលែប និងលោកយ៉ូស្វេ ដែលពួកគាត់ទាំងពីរនាក់បាន ចូលក្នុងទឹកដីសន្យារួចមកហើយ។ ពួកគេបាននាំគ្នានិយាយថា៖ ‘ពួកយើងមិនអាចចូលទៅក្នុងទឹកដី សន្យា ហើយដណ្តើមយកទឹកដីនោះបានទេ។ ខ្មាំងសត្រូវដែលរស់នៅក្នុងទឹកដីនោះមានសមត្ថភាព និងកំឡាំងខ្លាំងណាស់ ’ ។ ផ្ទុយទៅវិញ ពួកគេបែរជានាំគ្នាវិលត្រលប់ទៅរស់នៅក្នុងវាលរហោស្ថាន វិញ ហើយក្រោយមកពួកគេបានបន្តការស្តីបន្ទោសប្រឆាំងនឹងព្រះជាម្ចាស់ទៀត នៅពេលដែល ពួកគេជួបទុក្ខលំបាកក្នុងវាលរហោស្ថាននោះ។

ឧទាហរណ៍បើលោកអ្នកកំពុងស្ថិតនៅក្នុងវាលរហោស្ថានថ្ងៃនេះ នោះមិនមែនព្រះជាម្ចាស់ទេ ដែលចង់អោយលោកអ្នករស់នៅទីនោះ។ ព្រះជាម្ចាស់មិនចង់អោយលោកអ្នករស់នៅក្នុងជីវិតមួយ ដែលធ្វើតាមរបៀបសាច់ឈាមលោកិយ៍នោះទេ។ ព្រះអង្គចង់អោយលោកអ្នករស់នៅក្នុងជីវិតមួយ ដែលពេញដោយព្រះវិញ្ញាណ ហើយមានអំណរពិតប្រាកដក្នុងព្រះពររបស់ព្រះជាម្ចាស់ និងទទួលផល ប្រយោជន៍ដែលបានមកពីការរួមប្រកបគ្នាជាមួយនឹងទ្រង់។ ប្រជាជនអ៊ីស្រាអែលមិនបានយល់អំពី បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយក៏មិនយល់ថាហេតុអ្វីបានជា ទ្រង់ធ្វើអោយមានសត្វពស់ ពិសក្នុងចំណោមពួកគេដែរ។ តាមពិតព្រះអង្គមានព្រះហឫទ័យចង់នាំពួកគេអោយត្រលប់មករកទ្រង់ វិញ។ លោកអ្នកឃើញទេថា មានពេលខ្លះដែលព្រះជាម្ចាស់អនុញ្ញាត្តអោយមានការលំបាកខ្លះៗចូល មកក្នុងជីវិតរបស់យើង គឺនៅពេលដែលយើងវង្វេងចេញពីព្រះអង្គ ហើយយើងបានបណ្តោយខ្លួនឯង អោយចូលទៅក្នុងទឹកដីដែលពោរពេញដោយភាពគ្រោះថ្នាក់។ ព្រះជាម្ចាស់ជ្រាបដឹងថា តាមរយៈ បទពិសោធន៍ដែលលំបាកទាំងនោះ នឹងផ្តល់ផលប្រយោជន៍ដល់យើង ដើម្បីរលឹកដាស់តឿនយើង អោយវិលត្រលប់ទៅរកព្រះជាម្ចាស់វិញ។ ដូចនេះ វាមិនមែនជាការដាក់ទោសរបស់ព្រះជាម្ចាស់មកលើ យើងនោះទេ។ ប៉ុន្តែព្រះអង្គកំពុងមានព្រះបន្ទូលថា៖ “ **ចូរត្រលប់មករកយើងវិញ អ្នករាល់គ្នាមិនអាច រស់នៅដោយគ្មានយើងបានទេ អ្នករាល់គ្នានឹងត្រូវបរាជ័យ។ ការរំខានផ្សេងៗ និង កិច្ចការលំបាក ព្រមទាំងបញ្ហាជាច្រើននឹងកើតឡើងដល់អ្នករាល់គ្នា ដោយព្រោះ អ្នករាល់គ្នាបានព្យាយាមរស់នៅ ដោយគ្មានយើង** ” ។ អ្វីៗទាំងអស់ត្រូវបានបង្កើតឡើង ដើម្បីនាំលោកអ្នកអោយត្រលប់ទៅកាន់ ព្រះជាម្ចាស់វិញ ព្រោះព្រះអង្គចង់អោយលោកអ្នកកើតជាថ្មីក្នុងព្រះវិញ្ញាណ ហើយរស់នៅក្នុងជីវិតដ៏ល្អ អស្ចារ្យមួយដែលរួមប្រកបនឹងទ្រង់។ បើគ្មានជំនួយពីព្រះអង្គទេនោះ ប្រជាជនអ៊ីស្រាអែលប្រាកដជា បាត់បង់ជីវិតនៅក្នុងវាលរហោស្ថាននោះបាត់ទៅហើយ។ ពួកគេប្រហែលជាមិនអាចរស់បានក្នុងរយៈ

ពេល ពីរសប្តាហ៍ផង ប៉ុន្តែដោយសារព្រះជាម្ចាស់ ព្រះអង្គបានធ្វើជាជំនួយរបស់ពួកគេ នោះពួកគេបានរស់នៅក្នុងវាលរហោស្ថាននោះអស់រយៈពេលរហូតដល់ ៤០ឆ្នាំ។ ដូចគ្នាដែរ ព្រះជាម្ចាស់កំពុងតែជួយលោកអ្នក ទោះបីជាលោកអ្នកកំពុងតែដើរឆ្លងកាត់វាលរហោស្ថានក្នុងពេលឥឡូវនេះក៏ដោយ។ ប្រសិនបើគ្មានព្រះហស្តរបស់ព្រះជាម្ចាស់ជួយយើងនោះទេ យើងនឹងមិនអាចបន្តជីវិតបានទៀតឡើយ។ ការរស់នៅរបស់លោកអ្នកមកដល់ថ្ងៃនេះ គឺបានមកដោយសារព្រះជាម្ចាស់ ជាអ្នកប្រទានអោយលោកអ្នក និងមនុស្សទាំងអស់។ ព្រះអង្គជួយលោកអ្នក ព្រោះព្រះអង្គចង់អោយលោកអ្នកបានស្គាល់សេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់ និងការព្រួយបារម្ភ ការខ្វល់ខ្វាយរបស់ទ្រង់ចំពោះជីវិតរបស់លោកអ្នក ព្រោះព្រះអង្គចង់ឃើញលោកអ្នកបានកើតជាថ្មីក្នុងនៅព្រះវិញ្ញាណ ហើយនឹងបានក្លាយជាមនុស្សដែលមានជីវិតពេញបរិបូរណ៌ ដូចជាអ្វីដែលព្រះជាម្ចាស់ចង់អោយមនុស្សយើងមានគ្រប់ៗគ្នាដែរ។

ឥឡូវនេះ មានមនុស្សលោកជាច្រើនកំពុងតែធ្វើដំណើរ នៅលើដងផ្លូវដែលនាំទៅរកគ្រោះថ្នាក់ និងការលំបាក។ ដូច្នេះ លោកអ្នកត្រូវតែត្រលប់មករកព្រះជាម្ចាស់វិញ មុនពេលដែលលោកអ្នកត្រូវបានបំផ្លាញ។ សេចក្តីសន្យាដ៏អស្ចារ្យមួយដែលព្រះជាម្ចាស់បានសន្យា គឺថាប្រសិនបើលោកអ្នកគ្រាន់តែជឿលើព្រះបុត្រារបស់ព្រះអង្គ នោះលោកអ្នកនឹងមិនត្រូវវិនាសឡើយ ប៉ុន្តែលោកអ្នកនឹងមានជីវិតអស់កល្បជានិច្ចវិញ។ ជីវិតអស់កល្បជានិច្ច មិនមែនជាចំនួនប៉ុន្មានឆ្នាំនោះទេ ប៉ុន្តែវាជាអ្វីដែលមានគុណភាពដ៏ល្អមួយ ហើយជាចំនួនដែលមិនអាចរាប់បាន។ លោកអ្នកឃើញទេថា ចំនួនដែលគ្មានគុណភាពនោះ គឺជាស្ថាននរក។ ប៉ុន្តែជីវិតនៅក្នុងព្រះវិញ្ញាណនឹងនាំអោយជីវិតរបស់យើងមានគុណភាព វិសេសជាងការយល់ដឹងរបស់ពពួកសត្វ (ឬរូបកាយ) ហើយលើសជាងការគិតរបស់យើងទៅទៀត។ នោះហើយ គឺជាជីវិតដែលព្រះជាម្ចាស់ទ្រង់កំពុងចង់អោយលោកអ្នកមាន។ នោះហើយជាជីវិតដែលនៅក្នុងព្រះវិញ្ញាណ ហើយជាជីវិតដែលរួមប្រកបជាមួយទ្រង់។ ព្រះគម្ពីរមានចែងថា៖ **គំនិតរបស់សាច់ឈាម គឺជាសេចក្តីស្លាប់ ប៉ុន្តែគំនិតនៃព្រះវិញ្ញាណ គឺជាជីវិត សេចក្តីសុខសាន្ត និងអំណរវិញ**។ នេះ គឺជាបំណងព្រះហឬទ័យរបស់ព្រះជាម្ចាស់សំរាប់លោកអ្នករាល់គ្នា គឺជាជីវិតអស់កល្បជានិច្ច សេចក្តីសុខសាន្ត និងអំណរ ហើយអំណរនេះ គឺជាអំណរដែលមកពីការ រស់នៅរួមប្រកបជាមួយព្រះជាម្ចាស់ ព្រមទាំងដឹងថា ទ្រង់គង់ជាមួយលោកអ្នក ដឹកនាំលោកអ្នក ហើយដឹងថាទ្រង់ជាព្រះដែលដឹងគ្រប់អ្វីៗទាំងអស់។

មនុស្សដែលកើតជាថ្មី គឺជាមនុស្សដែលជឿលើការផ្តល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះគេ ដើម្បីគេបានទទួលការអត់ទោសអោយបានរួចពីបាប ហើយព្រះយេស៊ូបានទទួលយកអំពើបាបទាំងនោះ ដាក់លើព្រះអង្គផ្ទាល់។ ដូច្នេះនៅពេលដែលលោកអ្នកជឿលើព្រះយេស៊ូ ហើយ

ទទួលយកទ្រង់ជាព្រះសង្គ្រោះ និងជឿថា ព្រះអង្គបានសុគតដើម្បីលះបាបរបស់លោកអ្នកមែន នោះការកើតជាថ្មីខាងវិញ្ញាណនឹងកើតឡើងយ៉ាងអស្ចារ្យនៅក្នុងជីវិតរបស់លោកអ្នក។ បន្ទាប់មកទៀតនោះលោកអ្នកនឹងបានរស់នៅយ៉ាងពេញលេញជាងមុនជាមួយនឹងជីវិតក្នុងព្រះវិញ្ញាណដែល លោកអ្នកមិនដែលនឹកស្មានដល់ ព្រមទាំងមិនដែលដឹងពីមុនមកផងដែរ។ វាពិតជាល្អអស្ចារ្យណាស់ ហើយក៏វិសេសហួសពីការគិត និងបទពិសោធន៍របស់មនុស្សទៅទៀតផង។ ការនេះ គឺជាការដែលមនុស្សលោកមិនអាចរកពាក្យយកមកពិពណ៌នាបានឡើយ។ សាវ័កប៉ូលបាននិយាយថា៖ *សេចក្តីដែលលោកបានពិសោធន៍នៅក្នុងព្រះវិញ្ញាណនោះ គឺវាពិតជាអស្ចារ្យណាស់ ហើយដែលអស្ចារ្យរហូតដល់មិនអាចរកពាក្យរបស់មនុស្សលោកណាមួយមកពណ៌នាអំពីការនោះបានសោះឡើយ* ។ ដូចនេះ គ្មានភាសាណាមួយដែលអាចពិពណ៌នាអំពីការនោះបានឡើយ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ ***ប្រសិនបើអ្នកចង់ឃើញព្រះរាជនៃស្ថានបរមសុខ និងចង់យល់អំពីវា នោះលោកអ្នកត្រូវតែកើតជាថ្មី។*** ដើម្បីបានចូលទៅក្នុងព្រះរាជនៃស្ថានបរមសុខបាន លោកអ្នកត្រូវតែបានកើតជាថ្មី។ លោកអ្នកគ្រាន់តែសំលឹងមើលទៅឯព្រះយេស៊ូគ្រិស្ត ដែលទ្រង់ត្រូវបានសុគតនៅលើឈើឆ្កាង ដើម្បីលះបាបលោកអ្នក និងមនុស្សទាំងអស់ ហើយជឿលើទ្រង់ ព្រមទាំងជឿលើសេចក្តីស្រឡាញ់របស់ទ្រង់ដែលមានសំរាប់លោកអ្នក នោះព្រះជាម្ចាស់នឹងផ្លាស់ប្រែលោកអ្នកជាមិនខាន។ ប៉ុន្តែមានសំណួរមួយ ដែលត្រូវចោទសួរថា៖ ***តើលោកអ្នកបានកើតជាថ្មីជាមួយព្រះវិញ្ញាណព្រះជាម្ចាស់ ហើយរឺនៅ?*** *ប្រសិនបើលោកអ្នកមិនទាន់កើតជាថ្មីទេនោះ ការកើតជាថ្មីមានលក្ខណៈងាយស្រួលណាស់*។

ឧទាហរណ៍ថា៖ ថ្ងៃនេះលោកអ្នកកំពុងតែស្ថិតនៅក្នុងជំរុំមួយក្នុងចំណោមជំរុំពីរផ្សេងគ្នា ហើយការស្ថិតនៅក្នុងជំរុំណាមួយរបស់លោកអ្នកនោះ គឺអាស្រ័យលើទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះយេស៊ូគ្រិស្ត។ លោកអ្នកអាចជឿ ហើយសំលឹងមើលទៅកាន់ព្រះយេស៊ូ ដោយមានជំនឿថាព្រះអង្គបានសុគតសំរាប់លោកអ្នកនៅលើឈើឆ្កាង ឬក៏លោកអ្នកអាចរស់នៅតាម របៀបសាច់ឈាមលោកិយ៍របស់លោកអ្នកបន្តទៅទៀត។ វាជាការងាយស្រួលណាស់សំរាប់លោកអ្នកក្នុងការបាត់បង់ឱកាសទទួលសេចក្តីសង្គ្រោះ គឺគ្រាន់តែលោកអ្នកមិនទទួលជឿលើព្រះយេស៊ូគ្រិស្ត នោះលោកអ្នកបានបាត់បង់ឱកាសនោះរួចទៅហើយ។ ប៉ុន្តែសូមចងចាំថា ការដែលលោកអ្នកកំពុងតែបន្តធ្វើទាំងនេះនឹងនាំអោយលោកអ្នកត្រូវវិនាសបាត់បង់។ ទន្ទឹមនឹងនេះដែរ ប្រសិនបើលោកអ្នកសំលឹងមើលទៅកាន់ឈើឆ្កាង និង ជឿថាព្រះយេស៊ូគ្រិស្តដែលបានសុគតជំនួសអំពើបាបរបស់លោកអ្នក នោះអំណោយនៃការសង្គ្រោះរបស់ព្រះជាម្ចាស់នឹងបានក្លាយទៅជារបស់លោកតែម្តងអ្នក។

ប្រសិនបើលោកអ្នកចង់បានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់ និងចង់បានការបញ្ជាក់ច្បាស់ថា អំពើបាបរបស់លោកអ្នកត្រូវបានព្រះអង្គអត់ទោសរួចហើយនោះ ខាងក្រោមនេះ គឺជាគំរូនៃសេចក្តីអធិស្ឋានមួយ ៖

*ព្រះបិតាអើយ ទូលបង្គំសូមចូលមករកព្រះអង្គ ដើម្បីសារភាពអំពើបាបរបស់ទូលបង្គំ និងសូមអោយព្រះអង្គអត់ទោសបាបអោយទូលបង្គំផងដែរ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គដែលទ្រង់បានសន្យាថាៈ ប្រសិនបើទូលបង្គំសារភាពអំពើបាបរបស់ទូលបង្គំ នោះព្រះអង្គស្មោះត្រង់នឹងអត់ទោសបាបអោយទូលបង្គំ ព្រមទាំងសំអាតទូលបង្គំអោយរួចពីសេចក្តីទុច្ចរិត និងអំពើបាបទាំងអស់របស់ទូលបង្គំផង។ ទូលបង្គំចង់បានការផ្លាស់ប្រែ ហើយឈប់ប្រព្រឹត្តអំពើបាប និងរស់នៅដើម្បីអោយស្របតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ។ ដូច្នេះ សូមព្រះអង្គជួយទូលបង្គំ ហើយអោយទូលបង្គំមានអំណាចតាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដើម្បីអោយទូលបង្គំអាចរស់នៅស្របតាមបំណងព្រះហឫទ័យទ្រង់បាន។ ទូលបង្គំសូមអរព្រះគុណដល់ព្រះយេស៊ូគ្រិស្តដែលទ្រង់បានសុគតនៅលើឈើឆ្កាង ហើយបានបង់ថ្លៃនៃអំពើបាបរបស់ទូលបង្គំ ព្រមទាំងរស់ឡើងវិញពីសេចក្តីស្លាប់ផងដែរ។ ឥឡូវនេះទូលបង្គំសូមទទួលយកទ្រង់ជាព្រះសង្គ្រោះរបស់ទូលបង្គំ ហើយទទួលយកទ្រង់ធ្វើជាម្ចាស់របស់ទូលបង្គំ ព្រមទាំងយកទ្រង់ជាមិត្តភក្តិរបស់ទូលបង្គំផងដែរ។ ទូលបង្គំសូមអរព្រះគុណ ព្រោះព្រះអង្គមានព្រះបន្ទូលថាៈ អស់អ្នកណាដែលមកឯទ្រង់ នោះទ្រង់នឹងមិនបោះបង់គេចោលឡើយ។ សូមអរព្រះគុណទ្រង់ដែលទ្រង់អោយទូលបង្គំមានជីវិតថ្មីក្នុងអង្គព្រះគ្រិស្ត។ ទូលបង្គំសូមចុះចូលជាមួយព្រះអង្គ សូមទ្រង់ប្រើទូលបង្គំអោយធ្វើអ្វីតាមដែលទ្រង់ចង់អោយទូលបង្គំធ្វើ។ ទូលបង្គំសូមអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។ អាម៉ែន!*

ហើយ បន្ទាប់មកមានអ្វីទៀត?

ប្រសិនបើលោកអ្នកបានសំរេចចិត្តទទួលយកព្រះយេស៊ូគ្រិស្ត ជាព្រះសង្គ្រោះរបស់លោកអ្នករួចហើយ នោះមានន័យថាលោកអ្នកបានកើតជាថ្មីហើយ។ ខាងក្រោមនេះមានចំណុចសំខាន់ខ្លះៗ ដែលអាចជួយលោកអ្នកអោយរីកចំរើនក្នុងជីវិតជាគ្រិស្តបរិស័ទ ៖

**ចំណុចទីមួយ** ៖ ការអធិស្ឋាន គឺដូចជាការនិយាយទូរស័ព្ទទៅកាន់ព្រះជាម្ចាស់ដែរ ហើយវាជាការសំខាន់ណាស់សំរាប់យើងក្នុងការចំណាយពេលនិយាយទៅកាន់ព្រះអង្គជារៀងរាល់ថ្ងៃ។ ប្រសិនបើយើងនិយាយទៅកាន់ព្រះជាម្ចាស់កាន់តែបានច្រើន នោះវាកាន់តែល្អ។
*ភីលីព ៤:៦*

**ចំណុចទីពីរ** ៖ ការអានព្រះគម្ពីរ! ព្រះគម្ពីរ គឺប្រៀបដូចជាសំបុត្រស្នេហាដែលមកពីព្រះជាម្ចាស់ដែរ។ កាលណាលោកអ្នកអានកាន់តែច្រើន នោះលោកអ្នកនឹងកាន់តែធ្លាក់ក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងកាន់តែយល់អំពីព្រះអង្គថែមទៀតផង។
*១ ពេត្រុស ២:២*

**ចំណុចទីបី** ៖ ការប្រកបគ្នា ជាការសំខាន់ដែលលោកអ្នកមានមិត្តភក្តិ ដើម្បីលោកអ្នកអាចចែកចាយពីជំនឿរបស់អ្នក និងដើម្បីអោយលោកអ្នកបានទទួលការលើកទឹកចិត្តផងដែរ។ ហេតុនេះហើយបានជា វាជាការសំខាន់ណាស់ដែលលោកអ្នកស្វែងរកព្រះវិហារណាដែលជឿលើព្រះគម្ពីរថា ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតមែន ។ នោះគឺជាកន្លែង ដែលលោកអ្នកអាចជួបជាមួយគ្រិស្តបរិស័ទដទៃទៀត។
*ហេប្រឺ ១០:២៤-២៥*

**ចំណុចទីបួន** ៖ ត្រូវធ្វើជាបន្ទាល់ដល់អ្នកដទៃ មានន័យថាលោកអ្នកគួរតែចេះចែកចាយជំនឿក្នុងព្រះអម្ចាស់យេស៊ូគ្រិស្តរបស់លោកអ្នកជាមួយនឹងអ្នកដទៃ។ សូមអធិស្ឋានអោយព្រះអង្គបើកសំដែង និងបង្ហាញពីរបៀបដែលលោកអ្នកត្រូវធ្វើ ដើម្បីធ្វើជាបន្ទាល់ដល់អ្នកដទៃ ហើយអនុញ្ញាតអោយព្រះអង្គប្រាប់លោកអ្នកថា នៅពេលណាដែលព្រះអង្គចង់អោយអ្នកធ្វើបន្ទាល់នោះ។
*ម៉ាកុស ១៦:១៥*

**សូមព្រះប្រទានពរដល់លោកអ្នក!!**

THE WORD
FOR TODAY

P.O. Box 8000, Costa Mesa, CA 92628
Website: www.twft.com
E-mail: info@twft.com